ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
..............

ក្រសួងសាធារណការ និង ដឹកជញ្ជូន
អគ្គនាយកដ្ឋានសាធារណការ
នាយកដ្ឋាន ផ្លូវថ្នល់
លេខ : ០៤៤......ផ.ថ

ភ្នំពេញ . ថ្ងៃទី៤ ខែ ០/ ឆ្នាំ ២០០៤

# សេចក្ដីណែនាំ
# ស្ដីពីការប្រើប្រាស់ផ្លូវថ្នល់

ដោយពិនិត្យឃើញថា ទោះបីមានគោលនយោបាយ ស្ដីពីការគ្រប់គ្រង និង ប្រើប្រាស់ដីធ្លី ច្បាប់ភូមិបាល ឆ្នាំ ២០០១ និង សេចក្ដីប្រកាសស្ដីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី របស់រាជរដ្ឋាភិបាល ក៏នៅតែមានភាពខ្វះខាតសណ្ដាប់ធ្នាប់ និង ភាពទទួលខុសត្រូវលើបញ្ហាប្រើប្រាស់ផ្លូវថ្នល់ ឱ្យបានធានាអាយុកាលយូរអង្វែង និង មានសុវត្ថិភាពចរាចរនោះ នាយកដ្ឋានផ្លូវថ្នល់ សូមធ្វើការណែនាំដូច ខាងក្រោម :

## ១. ស្ដីពីការប្រើប្រាស់ផ្លូវថ្នល់

- សេចក្ដីណែនាំនេះមានវិសាលភាពគ្របដណ្ដប់លើអ្នកប្រើប្រាស់ផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អ្នកប្រើប្រាស់ផ្លូវសាធារណៈត្រូវគោរពឱ្យបានត្រឹមត្រូវ តាមសេចក្ដីណែនាំនេះ ។

**សេចក្ដីណែនាំនេះកំណត់និយមន័យដូចខាងក្រោម :**

ក / **ផ្លូវជាតិ :**

- ផ្លូវដែលចំណុចចាប់ផ្ដើមពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់ទីរួមខេត្ត
- ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ទីរួមខេត្ត
- ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅភ្ជាប់នឹងផ្លូវជាតិ
- ផ្លូវផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

*. **ប្រភេទផ្លូវជាតិ :**

ផ្លូវជាតិបែងចែកជា ២ ការិត :

- ផ្លូវជាតិការិត 1 : ជាផ្លូវជាតិដែលមានលេខ ១ ខ្ទង់
- ផ្លូវជាតិការិត 2 : ជាផ្លូវជាតិដែលមានលេខ ២ ខ្ទង់

ខ / **ផ្លូវខេត្ត :**

1- ផ្លូវខេត្តជាផ្លូវដែលចេញពីខេត្ត ឆ្ពោះទៅកាន់ទីរួមស្រុក ។
2- ផ្លូវបែកចេញពីផ្លូវជាតិ ទៅផ្លូវខេត្ត ។
3- ផ្លូវបំបែកពីផ្លូវខេត្ត ឆ្ពោះទៅស្រុកក្នុងករណីចំនួនចរាចរមធ្យមប្រចាំថ្ងៃ ADT ធំជាងឬស្មើនឹង 50 ។
4- ផ្លូវបំបែកចេញពីផ្លូវខេត្ត ឆ្ពោះទៅផ្លូវខេត្ត ។
5- ផ្លូវជនបទ ក្នុងករណី ចំនួនមធ្យោបាយចរាចរមធ្យមប្រចាំថ្ងៃ ធំជាង ឬស្មើ 50 ( ADT) ។